01178060

002/19-09-2007-ECCC/TC
**E1/356**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 12 / 2015
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

# ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ២០១៥

# សវនាការលើអង្គសេចក្តី - ថ្ងៃ ៣៣៧

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Matthew J. McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, លោក Roger PHILLIPS, លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង លាង, លោក Dale LYSAK, លោក Vincent de WILDE d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក ឡោ ជុនធី, លោក ហុង គីមសួន, លោកស្រី ជេត វណ្ណលី, លោកស្រី ស៊ីន សុវ៉ន | |
| សាក្សី/ដើមបណ្តឹង៖ 2-TCW-996 | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ិច អរុណ | |
| ផ្សេងៗ៖ លោកស្រី សំ មករា, លោក ឡុង ង៉ែត, កញ្ញា ស៊ីម សុខជា, កញ្ញា Clementine PLAGNOL, លោក ឌុច ផារី (មេធាវីប្រឹក្សា) | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៩ | បញ្ចប់ម៉ោង៖ ១៦.០៦ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៤០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៤៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៩ | ០៩.១៤ |
| សេចក្តីសម្រេច អនុលោមតាមវិធាន ៧៩(៤) ក្នុងការបន្តកិច្ចដំណើរការនីតិវិធី | អង្គជំនុំជម្រះ | ០៩.១០ | ០៩.១១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.១៤ | ០៩.១៦ |
| សំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំផ្អាកកិច្ចដំណើការនីតិវិធីសវនាការ | មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ | ០៩.១៧<br>០៩.២៩<br>០៩.៣១<br>០៩.៣២ | ០៩.២៨<br>០៩.៣១<br>០៩.៣២<br>០៩.៣៥ |
| សំណើរបស់មេធាវីការពារក្តី ខៀវ សំផន និង សហព្រះរាជអាជ្ញា | អង្គជំនុំជម្រះ | ០៩.៣៥<br>០៩.៥៨ | ០៩.៤០<br>១០.០៦ |

| | | | |
|---|---|---|---|
| ស្នើសុំអង្គជំនុំជម្រះលុបចោលនូវសេចក្ដីបង្គាប់របស់ខ្លួន (ឯកសារ E319/7/3) ពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤ (សវនាការអសាធារណៈ) | មេធាវីការពារក្ដី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ១០.២៤<br>១១.៣៤<br>០៩.៤១<br>១០.០៦<br>១០.២១ | ១១.២៧<br>១១.៤០<br>០៩.៥៨<br>១០.២១<br>១០.២៤ |
| សេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះទៅលើសំណើសុំឱ្យអង្គជំនុំជម្រះលុបចោលសេចក្ដីបង្គាប់របស់ខ្លួន (E319/7/3) | អង្គជំនុំជម្រះ | ១៣.៣៥ | ១៣.៤៤ |
| ការតាំងសំណួរទៅសាក្សី 2-TCW-996 | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា | ១៣.៤៤<br>១៣.៥២<br>១៥.០៣ | ១៣.៥១<br>១៥.៥៣<br>១៥.៥៥ |
| សំណើរបស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារមួយ | មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១៥.៥៥<br>១៥.៥៨<br>១៦.០៤ | ១៥.៥៦<br>១៦.០០<br>១៦.០៥ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>សេចក្ដីសម្រេច អនុលោមតាមវិធាន ៧៩(៤) ក្នុងការបន្តកិច្ចដំណើរការនីតិវិធី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសថា អនុលោមតាមវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុង ចៅក្រម ធូ មណី (ចៅក្រមបម្រុង) នឹងជំនួសចៅក្រម យូរ ឧត្ដារ រហូតដល់ពេលចៅក្រម យូរ ឧត្ដារ មានវត្តមានវិញ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួម

កិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>សំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំផ្អាកកិច្ចដំណើការនីតិវិធីសវនាការ</u>**

មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំពេលវេលាបន្ថែមក្នុងការរៀបចំខ្លួនសម្រាប់សវនាការលើបណ្តឹងសារទុក្ខ និងសម្រាប់ការរៀបចំលើអង្គហេតុបន្ទាប់ក្នុងសំណុំរឿង ០០២/០២ គឺការប្រព្រឹត្តលើជនជាតិវៀតណាម។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា សំណើនេះមិនមែនគ្មានហេតុផលនោះទេ ប៉ុន្តែស្នើសុំឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សី ៣ នាក់ដែលបានគ្រោងទុកសិន មុននឹងផ្អាកសវនាការ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន នោះទេ ប៉ុន្តែបានធ្វើការកត់សម្គាល់ពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលថាការជំនុំជម្រះនឹងបញ្ចប់ក្នុងរយៈពេលសមស្រប។

អង្គជំនុំជម្រះបានផ្តល់នូវពេលវេលាបន្ថែមដល់ភាគី រយៈពេល ១ សប្តាហ៍គឺពីថ្ងៃទី ០២ រហូតដល់ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ក្នុងការរៀបចំខ្លួនសម្រាប់សវនាការលើបណ្តឹងសារទុក្ខ។ ដោយសារតែសាក្សីដែលគ្រោងមកផ្តល់សក្ខីកម្មនៅថ្ងៃ ពុធ និង សុក្រ ក្នុងសប្តាហ៍នេះពុំអាចមកផ្តល់សក្ខីកម្មបាននោះទេ ហេតុដូច្នេះអង្គជំនុំជម្រះនឹងពន្យាពេលសវនាការរហូតដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ បន្ទាប់ពីការស្តាប់សក្ខីកម្មសាក្សី 2-TCW-996 និង 2-TCW-868។

**<u>សំណើរបស់មេធាវីការពារក្តី ខៀវ សំផន និង សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះលុបចោលនូវសេចក្តីបង្គាប់របស់ខ្លួន (ឯកសារ E319/7/3) ពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤ (សវនាការអសាធារណៈ)</u>**

មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញនូវសេចក្តីណែនាំបន្ថែមរបស់ខ្លួនពាក់ព័ន្ធនឹងការប្រើប្រាសកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤ (ឯកសារ E319/7/3) ដោយសារថាសេចក្តីណែនាំនេះ នឹងតម្រូវឱ្យសវនាការប្រព្រឹត្តទៅជាអសាធារណៈ ដែលការណ៍នេះនឹងរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ។ មេធាវីការពារក្តី ខៀវ សំផន ស្នើឱ្យអង្គជំនុំជម្រះផ្អែកទៅលើសេចក្តីណែនាំពីដំបូងរបស់ខ្លួន (ឯកសារ E319/7)។

សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ស្នើថាអង្គជំនុំជម្រះគួរតែស្តាប់សក្ខីកម្មសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការជាសាធារណៈ ប្រសិនបើគ្មានបញ្ហាសន្តិសុខ ឬ បញ្ហាសម្ងាត់ណាមួយនោះ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ សន្និដ្ឋានថាការប្រើប្រាស់សេចក្តីណែនាំដំបូង (ឯកសារ E319/7) របស់អង្គជំនុំជម្រះគឺគ្រប់គ្រាន់ហើយ។

អង្គជំនុំជម្រះសម្រេចថា សេចក្ដីណែនាំដែលបានកែសម្រួលរបស់ខ្លួនពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយ (ឯកសារ E319/7/3) នៅតែមានសុពលភាពក្នុងពេលបច្ចុប្បន្ន ហើយអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មសាក្សី 2-TCW-996 និង 2-TCW-868 ជាអសាធារណៈ ហើយសំណួរដែលភាគីមានបំណងចោទសួរទៅកាន់សាក្សីទាក់ទិននឹងឯកសារក្នុងសំណុំរឿង ០០៣ និង ០០៤ គួរតែទុករហូតដល់ចុងបញ្ចប់នៃការផ្ដល់សក្ខីកម្មរបស់គាត់។ អង្គជំនុំជម្រះ ក្រោយពីមានការពិគ្រោះយោបល់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងកោសលុបប្រតិចារឹកនៃសវនាការថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥។ ចម្លើយតបជាក់លាក់របស់អង្គជំនុំជម្រះទៅនឹងសំណើរបស់ភាគីលើបញ្ហានេះ នឹងផ្ដល់ជូនក្នុងពេលសមស្របឆាប់ៗខាងមុខ។

**ការតាំងសំណួរទៅកាន់សាក្សី 2-TCW-996**

អង្គជំនុំជម្រះ និងមេធាវីការពារក្ដី នួន ជា បានតាំងសំណួរទៅកាន់សាក្សី 2-TCW-996។

**សំណើរបស់មេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន ៨៧(៣) នៃវិធាន ផ្ទៃក្នុង សុំឱ្យទទួលយកឯកសារមួយ**

បន្ទាប់ពីការតាំងសំណួរទៅកាន់សាក្សី 2-TCW-996 មេធាវីការពារក្ដី នួន ជា បានដាក់សំណើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារ D366/7.1.479 ដែលបានប្រើប្រាស់ក្នុងការសួរសំណួរទៅកាន់សាក្សីពាក់ព័ន្ធនឹងថ្នាំមកពីប្រទេសចិន។ អង្គជំនុំជម្រះបានសម្រេចយល់ព្រមតាមសំណើ និងទទួលយកឯកសារ D366/7.1.479 ដាក់ចូលជាឯកសារភស្តុតាង។

New E3

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9648 | D366/7.1.479 | 00233530-00233531; 00072601-00072602; / | DK Ministry of Commerce statistics table entitled "Ministry of Commerce, medicine from China date 1-14 August 1976" | P | 0008497 0008498 0008499 | 00143452 | / |

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/160 | / | 00852122-00852124; 00143036-00143459; / | The Khmer Rouge Communication Document 1975-1978 | P | 0008497 0008498 0008499 | 00143452 | / |
| E3/9094 | / | 00734030-00734120; 00728641-00728705 01123606-01123663 | Statement of PAN Chhuong (DC-Cam) | P | 00734075 | 00728673 | 01123635 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9564 | / | 01003875-01003890, 01044791-01044810 | Written Record of Interview of [2-TCW-996] | SC | 01003885 | 01044804 01044805 | / |
| E3/9 | D222/1.15 | / 00396177-00396757; 00639445-00640068 | Book by Philip Short entitled "Pol Pot, The History of a Nightmare" | P | / | 00396327 | 00639638 |
| E3/9076 | / | 00728841-00728896; 00731151-00731190; / | Statement of [REDACTED] (DC-Cam) | P | 00728848 00728849 00728868 00728870 00728871 00728872 00728880 00728881 | 00731156 00731170 00731172 00731179 | / |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- សេចក្ដីសម្រេចតាមវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុង តែងតាំងចៅក្រម ធូ មណី ជំនួសកន្លែងចៅក្រម យូរ ឧត្ដរា រហូតដល់ពេលគាត់មានវត្ដមានវិញ។ (០៩.០៩)
- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្ដតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្ដសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១៤)
- សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ពាក់ព័ន្ធនឹងការពន្យាពេលសវនាការ។

(១៣.៣៨)

- សម្រេចបន្តគោរពតាមសេចក្តីណែនាំដែលបានកែសម្រួល (ឯកសារ E319/7/3) ពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤។ (១៣.៣៩)
- សម្រេចយល់ព្រមតាមសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួលយកឯកសារ D366/7.1.479 ជាឯកសារភ័ស្តុតាង។ (១៤.០៤)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥។ (១៦.០៦)

| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីទហ៊ាង Matthew J. McCARTHY